# ជីវិតរបស់សត្វផ្សោតទន្លេមេគង្គ

## មាតិការ


១. សេចក្តីផ្តើម........................................ ២

២. លក្ខណៈទូទៅរបស់សត្វផ្សោតទន្លេមេគង្គ........................................ ៣

៣. ការចិញ្ចឹមជីវិតរបស់សត្វផ្សោតទន្លេមេគង្គ........................................ ៤

៤. ការបន្តពូជរបស់សត្វផ្សោតទន្លេមេគង្គ........................................ ៤

៥. លក្ខណៈពិសេសរបស់សត្វផ្សោតទន្លេមេគង្គ........................................ ៥

៦. ភាពខុសគ្នារវាងសត្វផ្សោត និង ត្រី........................................ ៦

៧. ការស្លាប់របស់សត្វផ្សោតទន្លេមេគង្គ........................................ ៧

៨. ការអភិរក្សសត្វផ្សោតទន្លេមេគង្គ........................................ ៨

៩. ផែនការរៀបចំ និងការអភិរក្សធនធានសត្វផ្សោតទន្លេមេគង្គនៅក្នុង ខេត្តក្រចេះ ៩

៩. ១. ការបង្កើតគោលនយោបាយក្នុងការរៀបចំ និងអភិរក្សសត្វផ្សោតទន្លេមេគង្គ................៩-១០

១០. ការរៀបចំគំរោងផែនអោយមានភាពទាក់ទាញនៅតំបន់អន្លង់ផ្សោតកាំពី .១១

ផែនទីនៃភូមិកាំពី (ឧបសម្ព័ន្ធ នៃភូមិកាំពី)........................................ ១២

១១. សេចក្តីសន្និដ្ឋាន........................................ ១៣

១២. អនុសាសន៍........................................ ១៤

១៣ ឯកសារស្រាវជ្រាវ ........................................ ១៥

# ជីវិតរបស់សត្វផ្សោតទន្លេមេគង្គ

## ១~សេចក្តីផ្តើម

ប្រទេសកម្ពុជា ជាប្រទេសមួយដែលសំបូរទៅដោយភោគទ្រព្យវប្បធម៌ និងធម្មជាតិក្នុងខេត្តក្រុងនានាទូទាំងប្រទេស។ ប្រទេសកម្ពុជាដែលល្បីល្បាញ និងរីកសុះសាយខាងសម្បត្តិវប្បធម៌ ដូចជាប្រាង្គប្រាសាទអង្គរវត្តដែលបានរាប់បញ្ចូលជាសម្បត្តិបេតិកភណ្ឌទី៧នៅលើពិភពលោក និងបណ្តាប្រាង្គប្រាសាទនានាទៀតដែលមាននៅពាសពេញផ្ទៃប្រទេសកម្ពុជា។ ប៉ុន្តែ ប្រទេសកម្ពុជាក៏សំបូរទៅដោយសម្បត្តិធម្មជាតិដែលមិនចាញ់ប្រទេសនានាដែលនៅជុំវិញខ្លួនដែរ ព្រោះប្រទេសកម្ពុជាជាប្រទេសមួយដែលមានអំណោយផលពីធម្មជាតិ ហើយធម្មជាតិទាំងនោះមានលក្ខណៈ ធម្មជាតិពិត១ដោយគ្មានការកែច្នៃឡើយ។ តួយ៉ាងដូចជាតំបន់មួយដែលស្ថិតនៅក្នុងខេត្តក្រចេះដែលល្បីថាជាតំបន់អេកូទេសចរណ៍ (Eco-Tourism)ដែលមានលក្ខណៈជាធម្មជាតិពិត១ ហើយព្រមទាំងមានការរស់នៅរបស់ថនិកសត្វមួយប្រភេទដែលយើងទាំងអស់គ្នាចង់ដឹងនឹងចង់ស្គាល់នោះ គឺជាប្រភេទសត្វផ្សោតទឹកសាបនៃទន្លេមេគង្គដែលស្ថិតនៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែងនៃព្រះរាជាណាចក្រកម្ពុជា ។




ម្យ៉ាងទៀតប្រភេទសត្វផ្សោតទឹកសាបនេះ ដែលគេអោយឈ្មោះថា **សត្វផ្សោតទន្លេមេគង្គ (Mekong Dolphin Or Irawaddy Dolphin)** ដែលវាមានជំរករស់នៅក្នុងតំបន់កាំពីនៃខេត្តក្រចេះ។ ខេត្តក្រចេះក៏ជាតំបន់ទេសចរណ៍មួយដែលមានភាពទាក់ទាញជា ខ្លាំងពីសំណាក់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ពីព្រោះទីនេះជាតំបន់ធម្មជាតិដែលមានពពួកថនិកសត្វផ្សោតរស់នៅ។ លើសពីនេះនៅតំបន់កាំពីក៏មានភូមិសាស្ត្រល្អអំណោយផលទាំងអាកាសធាតុ មច្ឆា សត្វផ្សោតទន្លេមេគង្គ និងតំបន់ទេសចរណ៍ជាច្រើនកន្លែងទៀត។ ម្យ៉ាងទៀតនៅតំបន់អន្លង់កាំពីនេះដែរនៅ រដូវប្រាំងយើងអាចមើលឃើញសំរស់របស់កោះជាច្រើននៅតាមដងទន្លេមេគង្គ និងការជិះទូកទស្សនាកំសាន្តមើលពីការរស់នៅរបស់សត្វផ្សោត និងជីវៈចំរុះជាច្រើនប្រភេទទៀតនៃខេត្តក្រចេះ។

## ២. លក្ខណៈទូទៅរបស់សត្វផ្សោតទន្លេមេគង្គ



សត្វផ្សោតទន្លេមេគង្គជាប្រភេទសត្វមួយដ៏កំរមួយនៅលើពិភពលោក ហើយសត្វផ្សោតប្រភេទទឹកសាបនេះមានរស់នៅតាមតំបន់អន្លង់នៃដងទន្លេមេគង្គភាគអាស៊ីអាគ្នេយ៍ ដូចជាប្រទេសកម្ពុជា និងប្រទេសឡាវ ។ ដោយឡែកនៅក្នុងប្រទេសកម្ពុជាសត្វផ្សោតប្រភេទទឹកសាបគឺមាននៅតែក្នុងតំបន់អន្លង់តាមដងទន្លេមេគង្គដែលស្ថិតនៅក្នុងទឹកដីខេត្តក្រចេះ និងខេត្តស្ទឹងត្រែងជាតំបន់ អេកូទេសចរណ៍ ( Eco-Tourism ) ព្រោះអនុគ្រោះដល់ការរស់នៅរបស់សត្វផ្សោតនេះ ។ សត្វផ្សោតប្រភេទទឹកសាបនេះគេអោយឈ្មោះថា **សត្វផ្សោតទន្លេមេគង្គ (Mekong Dolphin)** ដោយយោងតាមការរស់នៅរបស់វាតាមដងទន្លេមេគង្គ ចំណែកឯប្រជាជននៅក្នុងតំបន់នេះបានដាក់ឈ្មោះរបស់សត្វផ្សោតនេះថា **សត្វផ្សោតក្បាលត្រឡោក** យាងទៅតាមការមើលឃើញរបស់ពួកគេថាសត្វផ្សោតនេះក្បាលរបស់វាដូចជា ត្រឡោកអញ្ចឹង ។

បច្ចុប្បន្នសត្វផ្សោតទន្លេមេគង្គនេះមានចំនួនតិចតួចបំផុតគឺប្រហែល ១៥០ក្បាលប៉ុណ្ណោះដោយគិតតាមតួលេខពីតំបន់អន្លង់ផ្សោតកាំពីស្ថិតក្នុងខេត្តក្រចេះ រហូតដល់ព្រំប្រទល់ប្រទេសឡាវ-កម្ពុជា (ខេត្តស្ទឹងត្រែង-ល្បាក់ខោន) ដែលមានអន្លង់សំរាប់សត្វផ្សោតរកស៊ី និងវាមានកន្លែងរស់នៅទាំងអស់ចំនួន ៩អន្លង់ ។ ខេត្តដែលសំបូរសត្វផ្សោតជាងគេនៅក្នុងប្រទេសកម្ពុជា គឺស្ថិតនៅក្នុងខេត្តក្រចេះ-ខេត្តស្ទឹងត្រែង ហើយតំបន់ដែលសំបូរសត្វផ្សោតជាងគេគឺតំបន់អន្លង់កាំពីដែលប្រជាជនរស់នៅក្នុងតំបន់នេះបានហៅថា **តំបន់អន្លង់ផ្សោតកាំពី** ព្រោះតំបន់អន្លង់មួយនេះមានសត្វផ្សោតប្រហែលពី ២៥ ដល់ ៣៥ ក្បាលឯណោះ គឺមានចំនួនសត្វផ្សោតរស់នៅច្រើនជាងតំបន់អន្លង់ដទៃទៀត ។ សត្វផ្សោតទន្លេមេគង្គនេះការរស់នៅរបស់វា មានលក្ខណៈជាហ្វូង ឬជួនកាលមានលក្ខណៈតែឯងដោយវាធ្វើការហែលចល័តចុះឡើងតាមដងទន្លេមេគង្គ ពីព្រំប្រទល់ប្រទេសកម្ពុជាទៅដល់ព្រំប្រទល់ប្រទេសឡាវ ។ តំបន់ដែលវារស់នៅគឺតំបន់អន្លង់ដែលមានជំរៅ ទឹកជ្រៅៗជួនកាលវាអាចរស់នៅក្នុងជំរៅទឹករាក់ ១.៥ ម៉ែត្រ ហើយពេលខ្លះអាចធ្វើអោយវានឹងគីនខ្លួននៅលើច្រាំងដោយសារទឹករាក់ពេក ។ សត្វផ្សោតមួយក្បាលអាចរស់បានរហូតដល់ទៅ ៦០-៧០ឆ្នាំ (រស់តាមលក្ខណៈធម្មជាតិរហូតដល់ពេលវាចាស់ស្លាប់) គឺមានទំងន់ចាប់ពី ១៧០-២៧០គីឡូ (នៅពេលដែលវាពេញវ័យរហូតដល់អាយុវាចាស់) ប្រវែងរបស់វាមាន ២.៧៥ ម៉ែត្រនៅពេលវាមានអាយុ ២៦ឆ្នាំ ហើយនៅរាល់១៥នាទីម្តងគឺវាងើបពីទឹកម្តងដើម្បីដកដង្ហើម ព្រោះវាមិនអាចសំងំទៅក្នុងទឹកបានយូរទេដោយគ្មានខ្យល់ដកដង្ហើមទេ ។

## ៣. ការចិញ្ចឹមជីវិតរបស់សត្វផ្សោតទន្លេមេគង្គ



សត្វផ្សោតទន្លេមេគង្គ គឺជាថនិកសត្វចិញ្ចឹមជីវិតដោយការស៊ីត្រីជាអាហារ (ស៊ីតែពាក់កណ្តាលខ្លួនចុះក្រោម) ហើយវាធ្វើការហែលរកចំណី (ត្រី) នៅតាមតំបន់អន្លង់ ព្រោះតំបន់អន្លង់ជាតំបន់ដែលមានទឹកត្រជាក់ ហើយសំបូរត្រីជាងតំបន់នានានៅតាមដងទន្លេមេគង្គ ចាប់ពីតំបន់អន្លង់ផ្សោតកាំពីរហូតដល់ព្រំប្រទល់ប្រទេសឡាវ ។ គួបញ្ជាក់ដែលថា នៅរដូវទឹកឡើងគឺវាហែលរកស៊ីចល័តតាមអន្លង់នានា ហើយត្រឡប់មកកាន់កន្លែងដើមវិញនៅរដូវទឹកស្រក់ ព្រោះនៅរដូវទឹកឡើងមិនសូវសំបូរត្រីជាអាហាររបស់វាទេ ដូច្នេះវាត្រូវហែលចុះឡើងដើម្បីស្វែងរកចំណីរបស់វា (ត្រី) ។

## ៤. ការបន្តពូជរបស់សត្វផ្សោតទន្លេមេគង្គ



សត្វផ្សោត គឺជាថនិកសត្វមួយប្រភេទដែលរស់នៅក្នុងទឹកសាបដ៏កំរមាននៅលើពិភពលោកយើងនេះ ហើយសត្វផ្សោតប្រភេទនេះក៏ជិតដាច់ពូជទៅ ហើយនៅសល់ប្រហែល ១៥០ ក្បាលប៉ុណ្ណោះដែលមាននៅតាមតំបន់អន្លង់តាមដងទន្លេមេគង្គ (ពីតំបន់អន្លង់ផ្សោតប្រទេសកម្ពុជាស្ថិតក្នុងខេត្តក្រចេះទៅដល់តំបន់អន្លង់ផ្សោតព្រំប្រទល់ប្រទេសឡាវ) ។ អាយុរបស់ផ្សោតដែលអាចបន្តពូជបានគឺចាប់ពី ៧-៩ឆ្នាំ ឡើងទៅការបន្តពូជរបស់វា គឺស្ថិតនៅក្នុងតំបន់ដែលមានទឹករាក់ៗ ព្រោះងាយស្រួលក្នុងការដកដង្ហើម (មានគ្នាវាជួយដោលអោយដកដង្ហើមផងដែរ) ហើយការបន្តពូជរបស់សត្វផ្សោតគឺ ២-៣ឆ្នាំមានកូនមួយ (យោងតាមការស្រាវជ្រាវរបស់ក្រុមអ្នកវិទ្យាសាស្រ្ត) កូនផ្សោតដែលកើតមកមានទំងន់ពី ៨-១២គីឡូ ។ សត្វផ្សោតការបង្កកំណើតរបស់វា គឺដូចជាមនុស្សដែរចំណែកឯការចិញ្ចឹមកូនរបស់វាក៏ដូចជាមនុស្សដែរ គឺវាចិញ្ចឹមកូនដោយទឹកដោះ ។ ក្រោយពីការកើតកូនបានមួយអាទិត្យ គឺវាបណ្តើរកូនរបស់វារហូតដល់អាយុ១ឆ្នាំ ហើយក្រោយពីកូនផ្សោតចាប់ពីអាយុ១ឆ្នាំឡើងទៅមេរបស់វាឈប់អោយ បៅដោះដោយអោយកូនរបស់វាធ្វើការហែលរកចំណី (ត្រី) ដោយខ្លួនឯង (ប៉ុន្តែ មេនិងកូនផ្សោតគឺនៅតែ រស់នៅជាមួយគ្នា) ។